**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/២៤១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងផ្តល់នូវកិច្ចគាំពារ ដើម្បីរក្សាលំនឹងជីវភាពរស់នៅ សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីវិធាន នីតិវិធី និងយន្តការគ្រប់គ្រង ព្រមទាំងផ្តល់ការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ប្រាក់ឧបត្ថម្ភ និងលក្ខខណ្ឌនៃការទទួលផល

**មាត្រា៤.-**

គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ÷

- មានប័ណ្ណសមធម៌ ដែលមានសុពលភាព ដោយឈរលើកម្រិតភាពក្រីក្រ÷ ក្រកម្រិត១ (ទីទ័លក្រ) ឬក្រកម្រិត ២ (ក្រ) និង
- បានទៅផ្ទៀងផ្ទាត់បញ្ជីឈ្មោះនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅសាលាឃុំ សង្កាត់ណាមួយ។

**មាត្រា៥.-**

គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធមិ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ដូចខាងក្រោម ÷

១. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទីប្រជុំជនក្នុងរាជធានីភ្នំពេញ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធមិ(ប្រភេទ១ និងប្រភេទ ២) | ១២០ ០០០ រៀល | ១២០ ០០០ រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ៥២ ០០០ រៀល | ៣៦ ០០០ រៀល |
| ៣ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៦ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០រៀល | ២៨ ០០០ រៀល |

២. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទីប្រជុំជនក្រៅពីរាជធានីភ្នំពេញ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធមិ(ប្រភេទ១ និងប្រភេទ ២) | ១២០ ០០០ រៀល | ១២០ ០០០ រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៣ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០រៀល | ២៨ ០០០ រៀល |
| ៦ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០រៀល | ២៨ ០០០ រៀល |

៣. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅជនបទ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធមិ(ប្រភេទ១ និងប្រភេទ ២) | ៨០ ០០០ រៀល | ៨០ ០០០ រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៣ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៦ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ និងអនុវត្តកម្មវិធី

**មាត្រា៦.-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវដាក់ឱ្យអនុវត្តតាមរយៈយន្តការមានស្រាប់ ដែលកំពុងអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដោយឈរលើមូលដ្ឋានទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្រ ដែលធ្វើបច្ចុប្បន្នភាព ដោយក្រសួងផែនការ។

**មាត្រា៧.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ត្រូវចូលរួមអនុវត្ត និងផ្តល់កិច្ចគាំទ្រ ដើម្បីសម្រួលដល់ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទៅតាមតួនាទី និងភារកិច្ចស្របតាមស្មារតីនៃមាត្រា៨ ដល់មាត្រា១៣ នៃអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។

**មាត្រា៨.-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទៅតាមតួនាទី និងភារកិច្ច ដែលបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងលេខ ១២៧ ស.អ.យ.ប្រ.ក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមហាផ្ទៃ និងក្រសួងផែនការ។

## ជំពូកទី៤
## ការប្រើប្រាស់ទិន្នន័យ

**មាត្រា៩.-**

រាល់ទិន្នន័យគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជាកម្មវត្ថុនៃការរក្សាការសម្ងាត់។

**មាត្រា១០.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដែលទទួលអាណត្តិក្នុងការបើកផ្តល់សាច់ប្រាក់ជូនអ្នកទទួលផល ដោយមានកំណត់លក្ខខណ្ឌនៃការរក្សាការសម្ងាត់នៃទិន្នន័យឯកជន។

គ្រឹះស្ថានហិរញ្ញវត្ថុ ដែលទទួលអាណត្តិក្នុងការបើកផ្តល់សាច់ប្រាក់ជូនអ្នកទទួលផល ត្រូវប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រ និងងាយរងគ្រោះ សម្រាប់តែគោលបំណងនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

## ជំពូកទី៥
## នីតិវិធី និងដំណើរការនៃការអនុវត្តកម្មវិធី

**មាត្រា១១.-**

នីតិវិធី និងដំណើរការនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៦
## ថវិកាអនុវត្តកម្មវិធី

**មាត្រា១២.-**

រាល់ការចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវហិរញ្ញប្បទានដោយថវិកាជាតិ។

## ជំពូកទី៧
## ការតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធី

**មាត្រា១៣.-**

របាយការណ៍ និងការចុះពិនិត្យការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវអនុវត្តស្របតាមស្មារតីនៃមាត្រា ១៧ ដល់មាត្រា១៩ នៃអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ ត្រូវទទួលភារកិច្ចក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ទាំងក្នុងអំឡុងពេលអនុវត្ត និងក្រោយពេលបិទបញ្ចប់ការអនុវត្តកម្មវិធី។

## ជំពូកទី៨
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា ១៤.-**

យន្តការ និងនីតិវិធីនៃការដោះស្រាយវិវាទ ឬបណ្តឹងនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវអនុវត្តតាមរយៈយន្តការមានស្រាប់ ដែលកំពុងអនុវត្តសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។

## ជំពូកទី៩
## រយៈពេលនៃការអនុវត្ត

**មាត្រា១៥.-**

កាលបរិច្ឆេទ និងរយៈពេលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**មាត្រា១៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ